**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# រវាង
# ក្រុមហ៊ុន វ៉ាយ អិល ធី អុិនធើណេសិនណាល
# និង
# តំណាងប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន វ៉ាយ អិល ធី អុិនធើណេសិនណាល
# ស្តីពី
# ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ដោយរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩

ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង១៥នាទីរសៀល នៅក្រុមហ៊ុន វ៉ាយ អិល ធី អុិនធើណេសិនណាល ។ មានអាស័យដ្ឋាន: ផ្លូវជាតិលេខ១ ភូមិសទ្ធា ឃុំរំចេក ស្រុកព្រះស្តេច ខេត្តព្រៃវែង បានរៀបចំកិច្ចប្រជុំរវាងក្រុមហ៊ុន វ៉ាយ អិល ធី និងប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ។

នៅក្នុងអង្គប្រជុំ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្នប្រឈមមុខបញ្ហាខ្លាំងដោយ មិនមានការបញ្ជាទិញពីក្រុមហ៊ុននៅប្រទេសជប៉ុន ដោយសារប្រទេសជប៉ុនរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩ ជាហេតុធ្វើអោយក្រុមហ៊ុននៅប្រទេសជប៉ុនត្រូវបានបិទទ្វារ។ ម្យ៉ាងវិញទៀតក្រុមហ៊ុន វ៉ាយ អិល ធី អុិនធើណេសិនណាល មានអ្នកបញ្ជាទិញតែមួយប្រទេសគត់គឺនៅប្រទេសជប៉ុន ដែលជាហេតុធ្វើអោយផលិតកម្មមិនមានការងារធ្វើ និងតម្រូវអោយមានការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតសរុបចំនួន១០០នាក់ ក្នុងចំណោមកម្មករនិយោជិតសរុប ២០៦នាក់ រយៈពេល១ខែកន្លះ ដោយគិតចាប់ពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០២០ ចូលធ្វើការនៅថ្ងៃទី១ ខែ កក្កដា ឆ្នាំ ២០២០ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារភាគីទាំងពីរឯកភាពគ្នាដូចខាងក្រោម៖

១-ភាគីក្រុមហ៊ុនយល់ព្រមផ្តល់ប្រាក់ឧបត្ថម្ភចំនួន៧០ដុល្លារអាមេរិក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល១ខែ ។

២-សម្រាប់កម្មករនិយោជិត ត្រូវ៖

-ផ្តល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

-ផ្តល់លេខទូរស័ព្ទផ្ទាល់ខ្លួនដែលអាចទាក់ទងបានដល់ក្រុមហ៊ុន ដើម្បីក្រុមហ៊ុនចងក្រងជាបញ្ជីផ្តល់ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ យកទៅរៀបចំនីតិវិធីបើកផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល ប្រសិនបើគ្មានលេខទូរស័ព្ទផ្ទាល់ខ្លួន ត្រូវផ្តល់លេខទូរស័ព្ទជារបស់ប្តី ប្រពន្ធ កូន ឪពុក ម្តាយ ឬបងប្អូនបង្កើត និងមិនត្រូវប្តូរលេខទូរស័ព្ទជាដាច់ខាត។

-កម្មករនិយោជិតណាម្នាក់ ដែលខកខានក្នុងការផ្តល់លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងលេខទូរស័ព្ទដល់ក្រុមហ៊ុន គឺមានន័យថាសាម៉ីខ្លួនបានស្ម័គ្រចិត្តមិនទទួលយកប្រាក់ឧបត្ថម្ភរបស់



ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន វ៉ាយអិលធី អុិនធើណេសិនណាល YLT INTERNATIONAL CO., LTD. KINGDOM OF CAMBODIA

រាជរដ្ឋាភិបាលក្នុងរយៈពេលព្យួរកិច្ចសន្យាការងារ។

កិច្ចប្រជុំបានចប់នៅវេលាម៉ោង១៥និង០០នាទីរសៀល នៅថ្ងៃនៅខែឆ្នាំដដែល ភាគីទាំងពីរបានឯកភាពគ្នាដោយមានការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និងសហការគ្នាល្អ ។

ព្រៃវែង ថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០២០

**ប្រតិភូបុគ្គលិក**

ស្នាំមេដៃ

គង់ សុវណ្ណា សេរី រតនា សឿន គឹមសាន សៀក យ៉ា

នាយកក្រុមហ៊ុន

ហត្ថលេខា និងត្រា

KANG JONG KYU